ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បញ្ញត្តិករទូរគមនាគមន៍កម្ពុជា
លេខ :...១៤៧១.....ប.ក.ទ.ក.

# សេចក្តីសម្រេច
# ស្តីពី
# លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រេកង់

## បញ្ញត្តិករទូរគមនាគមន៍កម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១២/១៧៥ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១២ ស្តីពីការបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៨ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំងឯកឧត្តម ម៉ូវ ចរិយា ប្រធាននៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា សម្រាប់អាណត្តិទី២
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៨ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការតែងតាំងមន្ត្រីរាជការ នៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤០ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- បានឃើញប្រកាសលេខ ១៧៥ បទ.ប្រក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១២ ស្តីពីការផ្ទេរតួនាទី និងភារកិច្ចទៅបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- បានឃើញប្រកាសលេខ ០៧២ បទ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍ និងថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ
- បានឃើញប្រកាសលេខ ២០៨ បទ.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការទទួលស្គាល់យថាប្រភេទ (TYPE APPROVAL) លើបរិក្ខារវិទ្យុគមនាគមន៍ និងបរិក្ខារទូរគមនាគមន៍
- យោងតាមការចាំបាច់របស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា។

# សម្រេច
# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

សេចក្តីសម្រេចនេះមានគោលដៅផ្តល់ និងកំណត់ការប្រើប្រាស់លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រេកង់ជូនរូបវន្តបុគ្គល ឬ នីតិបុគ្គលធ្វើអាជីវកម្ម ឬ ប្រើប្រាស់ដោយស្របតាមលក្ខខណ្ឌនៃសេចក្តីសម្រេចនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធ។



កាច់ផ្លូវវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
(ក្នុងបរិវេណក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍)
(855) 23 72 23 33
(855) 23 72 32 22
info@trc.gov.kh
www.trc.gov.kh

**ប្រការ២.-**

សេចក្តីសម្រេចនេះមានគោលបំណងដូចខាងក្រោម៖

- សម្រួលដល់ការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រេកង់ស៍
- ធានាប្រសិទ្ធភាពការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍ និងប្រេកង់ស៍
- ធានាដល់អ្នកធ្វើអាជីវកម្ម ឬ អ្នកប្រើប្រាស់បរិក្ខារវិទ្យុគមនាគមន៍ និងប្រេកង់ស៍គ្រប់ប្រភេទឲ្យមានប្រសិទ្ធភាព
- កាត់បន្ថយនូវភាពឆ្លងរំខាននៃការប្រើប្រាស់ប្រេកង់ស៍ លើកកម្ពស់សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គមក្នុងការប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍។

**ប្រការ៣.-**

សេចក្តីសម្រេចនេះមានវិសាលភាពអនុវត្តន៍ចំពោះរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលធ្វើអាជីវកម្ម ឬ ប្រើប្រាស់បរិក្ខារវិទ្យុគមនាគមន៍ និងប្រេកង់ស៍វិទ្យុក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រេកង់ស៍

**ប្រការ៤.-**

គ្មានរូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយអាចធ្វើអាជីវកម្ម ឬ ប្រើប្រាស់បរិក្ខារវិទ្យុគមនាគមន៍ និង/ឬ ប្រេកង់ស៍វិទ្យុ ដោយគ្មានលិខិតអនុញ្ញាត វិញ្ញាបនបត្រ និង/ឬ អាជ្ញាបណ្ណប្រេកង់ស៍មានសុពលភាពដែលផ្តល់ដោយបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។

**ប្រការ៥.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលអាចធ្វើអាជីវកម្ម ឬ ប្រើប្រាស់បរិក្ខារវិទ្យុគមនាគមន៍ និង/ឬ ប្រេកង់ស៍វិទ្យុបាន ត្រូវដាក់ពាក្យសុំនៅបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ដូចតទៅ៖

**ក. លិខិតអនុញ្ញាត**

១. លិខិតអនុញ្ញាតទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូល (ចែកចាយ) បរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍

២. លិខិតទទួលស្គាល់យថាប្រភេទនៃបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍ (Type Approval)

៣. លិខិតអនុញ្ញាតនាំចូលបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍។

**ខ. វិញ្ញាបនបត្រ**

១. វិញ្ញាបនបត្រប្រចាំឆ្នាំ នាំចូល លក់ និងជួសជុលបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍

២. វិញ្ញាបនបត្រប្រចាំឆ្នាំ លក់ និងជួសជុលបរិក្ខារវិទ្យុគមនាគមន៍ និងទូរគមនាគមន៍។

**គ. អាជ្ញាបណ្ណប្រេកង់ស៍**

១. អាជ្ញាបណ្ណប្រេកង់ស៍សម្រាប់ដំណើរការស្ថានីយវិទ្យុអាម៉ាទ័រ (Amateur Radio)

២. អាជ្ញាបណ្ណប្រេកង់ស៍សម្រាប់ដំណើរការស្ថានីយវិទ្យុទាក់ទងប្រភេទ MF, HF, VHF, UHF

៣. អាជ្ញាបណ្ណប្រេកង់ស៍សម្រាប់ដំណើរការស្ថានីយវិទ្យុផ្សាយសំឡេង AM, SW, FM

៤. អាជ្ញាបណ្ណប្រេកង់ស័សម្រាប់ដំណើរការស្ថានីយទូរទស្សន៍ប្រភេទ VHF, UHF
៥. អាជ្ញាបណ្ណប្រេកង់ស័សម្រាប់ដំណើរការស្ថានីយវិទ្យុ MICROWAVE
៦. អាជ្ញាបណ្ណប្រេកង់ស័សម្រាប់ដំណើរការផ្តល់សេវាទូរស័ព្ទចល័ត និងអចល័តឥតប្រើខ្សែ
៧. អាជ្ញាបណ្ណប្រេកង់ស័សម្រាប់ដំណើរការស្ថានីយវិទ្យុប្រដំបែន (Broadband Wireless Access)
៨. អាជ្ញាបណ្ណប្រេកង់ស័សម្រាប់ដំណើរការស្ថានីយវីសាត (VSAT)
៩. អាជ្ញាបណ្ណប្រេកង់ស័សម្រាប់ដំណើរការស្ថានីយ SATELLITE PHONE ឬ INMARSAT
១០. អាជ្ញាបណ្ណប្រេកង់ស័សម្រាប់ដំណើរការស្ថានីយផ្កាយរណប។

## ជំពូកទី៣
## កំណត់ការប្រើប្រាស់លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណប្រេកង់ស័

### ប្រការ៦.-

អ្នកកាន់លិខិតអនុញ្ញាត វិញ្ញាបនបត្រ និង/ឬ អាជ្ញាបណ្ណប្រេកង់ស័ ដែលផ្តល់ដោយបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម៖

**ក. អ្នកកាន់លិខិតអនុញ្ញាតទទួលស្គាល់យថាប្រភេទ (Type Approval)**

- ត្រូវរក្សាស្លាកសញ្ញាសម្គាល់(Label) ដែលផ្តល់ដោយបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវទទួលខុសត្រូវរាល់ការក្លែងបន្លំឯកសារ ឬគុណភាពនៃបរិក្ខារដែលបានផ្តល់ជូន
- លិខិតអនុញ្ញាតទទួលស្គាល់យថាប្រភេទ(Type Approval) នេះ មិនអនុញ្ញាតឲ្យលក់ ផ្ទេរ ឬធ្វើជាអំណោយទៅអ្នកដទៃដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីបញ្ញត្តិករទូរគមនាគមន៍កម្ពុជា។

**ខ. អ្នកកាន់វិញ្ញាបនបត្រនាំចូល លក់ និងជួសជុលបរិក្ខារវិទ្យុគមនាគមន៍**

- ត្រូវមានការអនុញ្ញាតពីបញ្ញត្តិករទូរគមនាគមន៍កម្ពុជា មុននឹងលក់បរិក្ខារវិទ្យុគមនាគមន៍
- មិនត្រូវដាក់បញ្ចូលលេខប្រេកង់ស័ប្រើប្រាស់បរិក្ខារវិទ្យុគមនាគមន៍ ដោយគ្មានការអនុញ្ញាតពីបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ចំពោះការបំពាក់អង់តែនវិទ្យុគ្រប់ប្រភេទសម្រាប់ធ្វើការសាកល្បងត្រូវមានលិខិតអនុញ្ញាតដោយឡែកពីបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវផ្តល់ដំណឹងទៅបញ្ញត្តិករទូរគមនាគមន៍កម្ពុជាអំពីឈ្មោះអ្នកទិញ អាសយដ្ឋាន លេខទូរស័ព្ទទំនាក់ទំនង និងចំនួនបរិក្ខារវិទ្យុដែលបានលក់ឲ្យអតិថិជន ដើម្បីជាមូលដ្ឋានសម្រាប់ការផ្ទៀងផ្ទាត់ចុះបញ្ជីអាជ្ញាបណ្ណប្រេកង់ស័
- ត្រូវគោរពតាមបទប្បញ្ញត្តិរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងការត្រួតពិនិត្យតាមការចាំបាច់។

**គ. អ្នកកាន់អាជ្ញាបណ្ណប្រេកង់ស័**

**១. វិទ្យុអាម៉ាទ័រ (Amateur Radio)៖**

- ត្រូវប្រើប្រាស់ប្រេកង់ស័ អានុភាពផ្សាយ ស្របតាមអាជ្ញាបណ្ណប្រេកង់ស័
- ត្រូវប្រើប្រាស់សម្រាប់តែក្នុងការសន្ទនា ការសិក្សាស្រាវជ្រាវ បច្ចេកវិទ្យា សង្គម វិទ្យាសាស្ត្រ ផ្តល់ចំណេះដឹង និងការជួយសង្គ្រោះតែប៉ុណ្ណោះ ដោយជៀសវាងការប្រើប្រាស់ដែលនាំឲ្យប៉ះពាល់ដល់សីលធម៌ និងសន្តិសុខសង្គម
- ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងការត្រួតពិនិត្យតាមតម្រូវការ។

**២. វិទ្យុទាក់ទង (Radiocom)៖**

- ត្រូវប្រើប្រាស់បន្ទារបង់ហ្វ្រេកង់ស៍ Y= 6 kHz ឬ Y =3 kHz ចំពោះបង់ហ្វ្រេកង់ស៍ប្រភេទ MF ឬ HF
- ត្រូវប្រើប្រាស់បន្ទារបង់ហ្វ្រេកង់ស៍ Y=25 kHz ឬ Y=12.5 kHz ចំពោះបង់ហ្វ្រេកង់ស៍ប្រភេទ VHF ឬ UHF
- ត្រូវប្រើប្រាស់បរិក្ខារវិទ្យុ ហ្វ្រេកង់ស៍ កម្ពស់អង់តែន និងអានុភាពផ្សាយ ស្របតាមអាជ្ញាបណ្ណហ្វ្រេកង់ស៍
- ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងការត្រួតពិនិត្យតាមតម្រូវការ។

**៣. វិទ្យុផ្សាយសំឡេង FM ៖**

- ត្រូវប្រើប្រាស់បរិក្ខារវិទ្យុ ហ្វ្រេកង់ស៍ កម្ពស់អង់តែន និងអានុភាពផ្សាយ ស្របតាមអាជ្ញាបណ្ណហ្វ្រេកង់ស៍សម្រាប់ដំណើរការស្ថានីយវិទ្យុផ្សាយសំឡេង
- ត្រូវបំពាក់ឧបករណ៍ បរិក្ខារចម្រោះ/តម្រង(Filter) ដើម្បីកាត់បន្ថយការផ្សាយចេញក្រៅបង់
- រាល់បង្គោលអង់តែនត្រូវបំពាក់ស្លាកសញ្ញាសំគាល់អត្តសញ្ញាណតាមការណែនាំរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវមានលិខិតបញ្ជាក់ទទួលខុសត្រូវនៃការដាក់ឲ្យដំណើរការដោយធានាថាមិនធ្លងរំខានដល់ហ្វ្រេកង់ស៍ស្ថានីយដទៃជូនក្រសួងព័ត៌មាន និងបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវផ្តល់ដំណឹងជូនបញ្ញត្តិករទូរគមនាគមន៍កម្ពុជា មុននឹងចាប់ផ្តើមផ្សាយសាកល្បង
- ត្រូវសហការជាមួយមន្ត្រីជំនាញរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជាក្នុងការត្រួតពិនិត្យស្ថានីយវិទ្យុ
- ត្រូវសហការសម្របសម្រួល និងដោះស្រាយរាល់បញ្ហាធ្លងរំខាន ដែលកើតមានឡើងពីការផ្សាយសំឡេង រវាងប្រតិបត្តិករ និងប្រតិបត្តិករ រួចធ្វើរបាយការណ៍ជូនក្រសួងព័ត៌មាន និងបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវប្រើប្រាស់ហ្វ្រេកង់ស៍ និងលក្ខណៈបច្ចេកទេសស្របតាមកិច្ចប្រជុំទ្វេភាគីស្តីពីការប្រើប្រាស់ និងសម្របសម្រួលការប្រើប្រាស់ហ្វ្រេកង់ស៍ តាមបណ្តោយព្រំដែនបណ្តាប្រទេសជិតខាង។

**៤. ទូរទស្សន៍ (Television) ៖**

- ត្រូវប្រើប្រាស់បរិក្ខារវិទ្យុ ហ្វ្រេកង់ស៍ កម្ពស់អង់តែន និងអានុភាពផ្សាយ ស្របតាមអាជ្ញាបណ្ណហ្វ្រេកង់ស៍សម្រាប់ដំណើរការស្ថានីយទូរទស្សន៍
- ត្រូវបំពាក់ឧបករណ៍ បរិក្ខារចម្រោះ/តម្រង (Filter) ដើម្បីកាត់បន្ថយការផ្សាយចេញក្រៅបង់
- រាល់បង្គោលអង់តែនត្រូវបំពាក់ស្លាកសញ្ញាសំគាល់អត្តសញ្ញាណតាមការណែនាំរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវមានលិខិតបញ្ជាក់ទទួលខុសត្រូវនៃការដាក់ឲ្យដំណើរការដោយធានាថាមិនធ្លងរំខានដល់ហ្វ្រេកង់ស៍ស្ថានីយដទៃ ជូនក្រសួងព័ត៌មាន និងបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវផ្តល់ដំណឹងជូនបញ្ញត្តិករទូរគមនាគមន៍កម្ពុជា មុនពេលចាប់ផ្តើមផ្សាយសាកល្បង
- ត្រូវសហការជាមួយមន្ត្រីជំនាញរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា ក្នុងការត្រួតពិនិត្យស្ថានីយទូរទស្សន៍
- ត្រូវសហការសម្របសម្រួល និងដោះស្រាយរាល់បញ្ហាធ្លងរំខានដែលកើតមានឡើងពីការផ្សាយទូរទស្សន៍រវាងប្រតិបត្តិករ និងប្រតិបត្តិករ រួចធ្វើរបាយការណ៍ជូនក្រសួងព័ត៌មាន និងបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវប្រើប្រាស់ហ្វ្រេកង់ស៍ និងលក្ខណៈបច្ចេកទេស ស្របតាមកិច្ចប្រជុំទ្វេភាគីស្តីពីការប្រើប្រាស់ និងសម្របសម្រួលការប្រើប្រាស់ហ្វ្រេកង់ស៍តាមបណ្តោយព្រំដែនបណ្តាប្រទេសជិតខាង។

**៥. វិទ្យុផ្តល់សេវាទូរស័ព្ទចល័ត/អចល័តឥតប្រើខ្សែ (Radio Base)៖**

- ត្រូវយកហ្វ្រេកង់ស៍ដែលបានផ្តល់ជូនដូចមានចែងក្នុងអាជ្ញាបណ្ណហ្វ្រេកង់ស៍ ទៅប្រើប្រាស់ឲ្យអស់លទ្ធភាពនៅតាមស្ថានីយផ្សាយ/ទទួល (BTS) និង Node B នីមួយៗ
- ត្រូវបំពាក់ឧបករណ៍ បរិក្ខារចម្រោះ/តម្រង (Filter) នៅគ្រប់បរិក្ខារវិទ្យុផ្សាយ/ទទួលទាំងអស់ ដើម្បីកាត់បន្ថយការផ្សាយស៊ីញ៉ាល់ចេញក្រៅបង់ (Out-of-Band Emission)

- ត្រូវមានលិខិតបញ្ជាក់ទទួលខុសត្រូវនៃការដាក់ឲ្យដំណើរការដោយធានាថាមិនឆ្លងរំខានដល់ហ្វ្រេកង់ស្ថានីយដទៃ ស្របតាមនិយាមរបស់សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) ឬប្រទេសក្នុងតំបន់ ជូនបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- រាល់បង្គោលអង់តែនត្រូវបំពាក់ស្លាកសញ្ញាសំគាល់អត្តសញ្ញាណតាមការណែនាំរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវផ្តល់របាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ នូវចំនួនស្ថានីយផ្សាយ/ទទួលជូនបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវសហការសម្របសម្រួល និងដោះស្រាយរាល់បញ្ហាឆ្លងរំខាន ដែលកើតមានឡើងពីការផ្តល់សេវាទូរស័ព្ទចល័ត អចល័តឥតប្រើខ្សែ រវាងប្រតិបត្តិករ និងប្រតិបត្តិករ រួចធ្វើរបាយការណ៍ជូនបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវសហការជាមួយមន្ត្រីជំនាញរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា ក្នុងការត្រួតពិនិត្យស្ថានីយផ្សាយ/ទទួល
- ត្រូវប្រើប្រាស់ហ្វ្រេកង់ស៍ និងលក្ខណៈបច្ចេកទេសស្របតាមកិច្ចប្រជុំទ្វេភាគីស្តីពីការប្រើប្រាស់ និងសម្របសម្រួលការប្រើប្រាស់ហ្វ្រេកង់ស៍តាមបណ្តោយព្រំដែនបណ្តាប្រទេសជិតខាង។

### ៦. វិទ្យុប្រដិបែន (Broadband Wireless Access)៖

- ត្រូវយកហ្វ្រេកង់ស៍ដែលបានផ្តល់ជូនដូចមានចែងក្នុងអាជ្ញាបណ្ណទៅប្រើប្រាស់ឲ្យអស់លទ្ធភាពនៅតាមស្ថានីយផ្សាយ/ទទួល (BTS) នីមួយៗ
- ត្រូវបំពាក់ឧបករណ៍ បរិក្ខារចម្រោះ/តម្រង (Filter) ដើម្បីកាត់បន្ថយការផ្សាយចេញក្រៅបង់
- រាល់ការផ្លាស់ប្តូរបច្ចេកវិទ្យាប្រដិបែនត្រូវជូនដំណឹងដល់បញ្ញត្តិករទូរគមនាគមន៍កម្ពុជាមុនពេលដំណើរការ
- ត្រូវមានលិខិតបញ្ជាក់ទទួលខុសត្រូវនៃការដាក់ឲ្យដំណើរការដោយធានាថាមិនឆ្លងរំខានដល់ហ្វ្រេកង់ស៍ស្ថានីយដទៃ ស្របតាមនិយាមរបស់សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) ឬប្រទេសក្នុងតំបន់ ជូនបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- រាល់បង្គោលអង់តែនត្រូវបំពាក់ស្លាកសញ្ញាសំគាល់អត្តសញ្ញាណតាមការណែនាំរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវផ្តល់របាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ នូវចំនួនស្ថានីយផ្សាយ/ទទួលជូនបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវសហការសម្របសម្រួល និងដោះស្រាយរាល់បញ្ហាឆ្លងរំខាន ដែលកើតមានឡើងពីការផ្តល់សេវាប្រដិបែនរវាងប្រតិបត្តិករ និងប្រតិបត្តិករ រួចធ្វើរបាយការណ៍ជូនបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវសហការជាមួយមន្ត្រីជំនាញរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា ក្នុងការត្រួតពិនិត្យស្ថានីយផ្សាយ/ទទួល

### ៧. វិទ្យុម៉ៃក្រូវ៉េវ (Microwave)៖

- រាល់ការកំណត់ទីតាំងប្រើប្រាស់ឡើងវិញនូវហ្វ្រេកង់ស៍ស្របតាមអាជ្ញាបណ្ណហ្វ្រេកង់ស៍ ត្រូវមានការអនុញ្ញាតជាថ្មីពីបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវសហការជាមួយមន្ត្រីជំនាញរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា ក្នុងការត្រួតពិនិត្យស្ថានីយវិទ្យុម៉ៃក្រូវ៉េវ
- រាល់បង្គោលអង់តែនត្រូវបំពាក់ស្លាកសញ្ញាសំគាល់អត្តសញ្ញាណតាមការណែនាំរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវផ្តល់របាយការណ៍អំពីចំនួនវិទ្យុម៉ៃក្រូវ៉េវ និងស្ថានីយផ្សាយ/ទទួល (BTS) ដែលភ្ជាប់ការប្រើប្រាស់វិទ្យុម៉ៃក្រូវ៉េវទៅបញ្ញត្តិករទូរគមនាគមន៍កម្ពុជាត្រឹមខែវិច្ឆិកានៃឆ្នាំនីមួយៗ
- ត្រូវប្រើប្រាស់ហ្វ្រេកង់ស៍ និងលក្ខណៈបច្ចេកទេសស្របតាមកិច្ចប្រជុំទ្វេភាគី ស្តីពីការប្រើប្រាស់

និងសម្របសម្រួលការប្រើប្រាស់ហ្វ្រេកង់ស៍តាមបណ្តោយព្រំដែនបណ្តាប្រទេសជិតខាង។

**៨. វិទ្យុវីសាត (VSAT)៖**

- ត្រូវផ្តល់របាយការណ៍ប្រចាំឆ្នាំអំពីការប្រើប្រាស់ស្ថានីយវីសាតជូនបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ត្រឹមខែវិច្ឆិកានៃឆ្នាំនីមួយៗ
- ត្រូវសហការជាមួយមន្ត្រីជំនាញរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា ក្នុងការត្រួតពិនិត្យស្ថានីយវីសាត។

**៩. Satellite Phone, Inmarsat ៖**

- ត្រូវផ្តល់របាយការណ៍ប្រចាំឆ្នាំអំពីការប្រើប្រាស់ស្ថានីយ Satellite Phone, Inmarsat ជូនបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ត្រឹមខែវិច្ឆិកានៃឆ្នាំនីមួយៗ
- ត្រូវសហការជាមួយមន្ត្រីជំនាញរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា ក្នុងការត្រួតពិនិត្យស្ថានីយវីសាត។

**១០. ផ្កាយរណប**

- មុនពេលបាញ់បង្ហោះចូលគន្លងតារាវិថី(Orbital) ត្រូវធ្វើការសម្របសម្រួលជាមួយបណ្តាប្រទេសពាក់ព័ន្ធដែលទទួលដែនសេវាគ្របដណ្តប់ (Footprint)
- ត្រូវរៀបចំឯកសារគ្រប់លក្ខណៈ ដើម្បីចុះបញ្ជីជាផ្លូវការនៅសហភាពទូរគមនាគមន៍អន្តរជាតិ តាមរយៈបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- ត្រូវដំណើរការស្ថានីយផ្កាយរណបដោយគោរពតាមនិយាម និងបទប្បញ្ញត្តិវិទ្យុរបស់សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) និង/ឬប្រទេសក្នុងតំបន់ និងស្របតាមខ្លឹមសារនៃអាជ្ញាបណ្ណ
- ត្រូវជូនដំណឹងដល់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា រាល់ការផ្លាស់ប្តូរបច្ចេកវិទ្យាសម្រាប់ដំណើរការផ្កាយរណប
- ត្រូវផ្តល់របាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំអំពីប្រតិបត្តិការផ្កាយរណប
- ត្រូវសហការជាមួយមន្ត្រីជំនាញរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា ក្នុងការត្រួតពិនិត្យស្ថានីយគ្រប់គ្រងប្រព័ន្ធផ្កាយរណប
- ត្រូវប្រើប្រាស់ស្ថានីយ និងបច្ចេកវិទ្យាផ្កាយរណប សម្រាប់បម្រើវិស័យទូរគមនាគមន៍ ស្របច្បាប់
- ត្រូវផ្តល់សេវាបណ្តាញទំនាក់ទំនងជូនរាជរដ្ឋាភិបាលក្នុងកិច្ចការសង្គ្រោះផ្សេងៗ ដូចជាគ្រោះមហន្តរាយធម្មជាតិ (ទឹកជំនន់ ខ្យល់ព្យុះ...) ជម្ងឺឆ្លង អគ្គីភ័យ និងឧបទ្ទវហេតុផ្សេងៗ។

## ជំពូកទី៤
## ការកែសម្រួល ព្យួរ ដកហូត ឬ បដិសេធលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណហ្វ្រេកង់ស៍

**ប្រការ៧.-**

បញ្ញត្តិករទូរគមនាគមន៍កម្ពុជាមានសិទ្ធិកែសម្រួល ព្យួរ ដកហូត ឬ បដិសេធ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណហ្វ្រេកង់ស៍ក្នុងករណីដូចខាងក្រោម៖

ក. ការកែសម្រួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ និង/ឬ អាជ្ញាបណ្ណហ្វ្រេកង់ស៍

- ក្នុងករណីអ្នកកាន់លិខិតអនុញ្ញាត វិញ្ញាបនបត្រ និង/ឬ អាជ្ញាបណ្ណហ្វ្រេកង់ស៍បានស្នើសុំជាលាយលក្ខណ៍អក្សរអំពីការផ្លាស់ប្តូរ អាសយដ្ឋាន អ្នកជានា នាមករណ៍អង្គភាព ឬក្រុមហ៊ុន និងបរិក្ខារវិទ្យុគមនាគមន៍។

ខ. ការព្យួរ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និង/ឬ អាជ្ញាបណ្ណហ្វ្រេកង់ស៍

- ក្នុងករណីអ្នកកាន់លិខិតអនុញ្ញាត ឬ វិញ្ញាបនបត្រ មិនបានអនុវត្តតាមលក្ខខណ្ឌដូចមានចែងត្រង់ចំណុច "ក" និង "ខ" ក្នុងប្រការ៦ នៃសេចក្តីសម្រេចនេះ និងត្រង់ចំណុច "ង" និង "ឋ" ក្នុងមាត្រា៣នៃព្រះរាជក្រឹត្យ ស្តីពីការបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា និងបទប្បញ្ញត្តិ

ផ្សេងៗទៀត ព្រមទាំងមិនបានគោរពតាមសេចក្តីណែនាំរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា

- ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណប្រេកង់ស៍មិនបានអនុវត្តតាមលក្ខខណ្ឌដូចមានចែងត្រង់ចំណុច "គ" ក្នុងប្រការ៦នៃសេចក្តីសម្រេចនេះ និងត្រង់ចំណុច "ង" និង "ឋ" ក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតបញ្ញត្តិករទូរគមនាគមន៍កម្ពុជា និងបទប្បញ្ញត្តិផ្សេងៗទៀតព្រមទាំងមិនបានគោរពតាមសេចក្តីណែនាំរបស់បញ្ញត្តិករទូរគមនាគមន៍កម្ពុជា ក្រោយពីការជូនដំណឹងចំនួនបីលើកដែលក្នុងមួយលើកមានរយៈពេល១០ថ្ងៃនៃថ្ងៃធ្វើការ
- ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណប្រេកង់ស៍មិនបានផ្តល់គម្រោងផែនការធុរៈកិច្ច បច្ចេកទេស និងពេលវេលាប្រតិបត្តិការច្បាស់លាស់ជូនបញ្ញត្តិករទូរគមនាគមន៍កម្ពុជាក្នុងរយៈពេល០១(មួយ)ឆ្នាំ។

គ. ការដកហូត ឬ បដិសេធ លិខិតអនុញ្ញាត វិញ្ញាបនបត្រ និង/ឬ អាជ្ញាបណ្ណប្រេកង់ស៍ក្នុងករណី៖

- លិខិតអនុញ្ញាត វិញ្ញាបនបត្រ និង/ឬ អាជ្ញាបណ្ណប្រេកង់ស៍ ត្រូវបានព្យួរក្នុងរយៈពេល ៣០ ថ្ងៃនៃថ្ងៃធ្វើការ
- មានតម្រូវការចាំបាច់ពីរាជរដ្ឋាភិបាល ឬ ការផ្លាស់ប្តូរនិយាមរបស់សហភាពទូរគមនាគមន៍អន្តរជាតិ (ITU) ក្នុងការប្រមូលយកមកវិញនូវវិសាលគមន៍ប្រេកង់ស៍វិទ្យុ សម្រាប់ប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាថ្មីៗ
- អ្នកកាន់អាជ្ញាបណ្ណប្រេកង់ស៍បានផ្ទេរ ឬធ្វើអំណោយប្រេកង់ស៍ ទៅរូបវន្តបុគ្គល ឬ នីតិបុគ្គលផ្សេងទៀតដោយគ្មានការអនុញ្ញាតពីបញ្ញត្តិករទូរគមនាគមន៍កម្ពុជា
- អ្នកកាន់អាជ្ញាបណ្ណប្រេកង់ស៍បានក្ស័យធន
- អ្នកកាន់អាជ្ញាបណ្ណប្រេកង់ស៍មិនបានយកប្រេកង់ស៍ទៅដំណើរការក្នុងរយៈពេល ០១(មួយ) ឆ្នាំបន្ទាប់ពីទទួលបានអាជ្ញាបណ្ណប្រេកង់ស៍
- ផ្លាស់ប្តូរប្រេកង់ស៍វិទ្យុ អានុភាពផ្សាយ ទីតាំងស្ថានីយ ឬ កែប្រែបរិក្ខារវិទ្យុខុសពីអាជ្ញាបណ្ណប្រេកង់ស៍ ឬ ច្នៃប្រឌិតភ្ជាប់បរិក្ខារបន្ថែម (ផ្នែករឹង និងផ្នែកទន់) ដោយគ្មានការអនុញ្ញាត។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ៨.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.-**

លេខាធិការដ្ឋាន និងគ្រប់អង្គភាពក្រោមឱវាទបញ្ញត្តិករទូរគមនាគមន៍កម្ពុជា ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១៥

**ប្រធាន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងព័ត៌មាន
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- គ្រប់សាលារាជធានី ខេត្ត " ដើម្បីជូនជ្រាប "
- ដូចប្រការ ៩ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ